**មាត្រា ៦ :** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១-០១-៩៤ តទៅ ។

ទេសរដ្ឋមន្ត្រី

និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**

* * *

ភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៤

# ប្រកាសលេខ 006 ប្រកសហវ

## ស្តីពី

## ការប្រព្រឹត្តទៅ នៃការងារអធិការកិច្ចរបស់ធនាគារជាតិ

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ២០-៩-៩០ របស់ក្រុមប្រឹក្សា រដ្ឋមន្ត្រី ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងហិរញ្ញវត្ថុ .
- តាមសំណើរបស់លោក ប្រធានធនាគារជាតិ

## សំរេច

**មាត្រា ១ :** ការងារអធិការកិច្ច នៃធនាគារជាតិ មានភារកិច្ចដូចខាងក្រោមនេះ :

- ត្រួតពិនិត្យការប្រព្រឹត្តទៅនៃធនាគារទូទាំងព្រះរាជាណាចក្រកម្ពុជា
- មើលបញ្ជាក់អំពីសេចក្តី នូវកិច្ចចុះបញ្ជីការគណនេយ្យ និង បេឡាបើកប្រាក់

នៃធនាគារជាតិ និង ធនាគារខេត្ត - ក្រុង ។

- ត្រួតពិនិត្យការរាប់ប្រាក់របស់ធនាគារក្នុងករណីមានការចាំបាច់ ។
- ចូលរួមជាមួយអធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងករណីដែលមានការត្រួត ពិនិត្យធនាគារ ហើយមានសំណូមពារអោយចូលរួម ។
- ចូលរួមបញ្ជូនមូលនិធិ " " អោយធនាគារខេត្ត - ក្រុង ។
- ទទួលពាក្យបណ្តឹងតវ៉ា និង ចូលរួមដោះស្រាយនូវរាល់បាតុភាពខុសឆ្គងរបស់មន្ត្រី រាជការដែលអនុវត្តខុសពីគោលការណ៍ទាំងឡាយរបស់ធនាគារជាតិ ។

**មាត្រា ២ :** ការត្រួតពិនិត្យត្រូវធ្វើឡើងទៅតាមបញ្ជារបស់ប្រធានធនាគារជាតិ ដោយយល់ឃើញថាមានប្រយោជន៍ ឬ ត្រូវតាមកាលៈទេសៈ ក្រោយពេលត្រួតពិនិត្យហើយ ត្រូវធ្វើកំណត់ហេតុ និង របាយការណ៍ពីលទ្ធផលរបស់ខ្លួន ជូនប្រធានធនាគារជាតិ ព្រមទាំងត្រូវចម្លងជូនមួយច្បាប់ទៅក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៣ :** មុនពេលត្រួតពិនិត្យ អ្នកត្រួតពិនិត្យត្រូវបង្ហាញលិខិតបេសកកម្ម ដែលប្រធានធនាគារជាអ្នក ចេញអោយ ។ ប្រធាន ឬ អនុប្រធានធនាគារខេត្ត - ក្រុង ប្រធាន ឬ អនុប្រធានបេឡា ប្រធាន ឬ អនុប្រធានគណនេយ្យ ត្រូវយល់ព្រមបើកបេឡា បង្ហាញសៀវភៅបញ្ជីការ សំបុត្រអាថ៌កំបាំង និង ឯកសារគណនេយ្យ ដែលអាចធ្វើអោយឃើញឥតខ្ចោះនូវការងាររបស់ខ្លួន ។

**មាត្រា ៤ :** ក្នុងកំណត់ពេលត្រូវធ្វើការត្រួតពិនិត្យនៅកន្លែងណាមួយ លិខិតអនុញ្ញាតឈប់សំរាក ឬ លំហែគ្រប់យ៉ាង ដែលប្រធាន ឬ អនុប្រធានធនាគារ. ប្រធាន ឬ អនុប្រធាន បេឡា ប្រធាន ឬ អនុប្រធានគណនេយ្យ ដែលមាននៅកន្លែងនោះ តែពុំទាន់បានប្រើនៅឡើយ ត្រូវផ្អាកសិន ។

**មាត្រា ៥:** ការត្រួតពិនិត្យ បេឡាត្រូវតែមើលបញ្ជាក់ក្នុងទីចំពោះមុខ ប៉ុន្តែបើជួបប្រទះ នូវសកម្មភាពរារាំង ឬ ពន្យាពេល ពេលត្រួតពិនិត្យដោយប្រធាន ឬ អនុប្រធាន ធនាគារ ប្រធាន ឬ អនុប្រធាន បេឡាត្រូវបាត់ខ្លួន ឬ មិនព្រមចូលរួមក្នុងកិច្ចការ មើលបញ្ជាក់ អ្នកត្រួតពិនិត្យត្រូវរាយការណ៍សុំ យោបល់លោកអភិបាលខេត្ត- ក្រុង ដើម្បីចាត់តាំង នគរបាលនិង តំណាងរបស់លោកមកចូលរួម ហើយការត្រួតពិនិត្យ នោះត្រូវយកជាការបាន ។

កាលបើពិនិត្យ ទៅឃើញគ្មានការបាត់បង់ទេ អ្នកត្រួតពិនិត្យត្រូវ សុំ យោបល់លោកអភិបាលខេត្ត - ក្រុង ដើម្បីចាត់តាំងអោយរាជការខេត្ត - ក្រុង ដែលប្រកបដោយសមត្ថភាព និង ទំនុកទុកចិត្តរ៉ាប់រងពីការ កាន់កាប់រតនាគារ បណ្ដោះអាសន្នសិន ។

កាលបើពិនិត្យ ទៅឃើញមានការបាត់បង់សាច់ប្រាក់ដោយលួច ឬ កែបន្លំ អ្នកត្រួតពិនិត្យ ត្រូវប្ដឹងទៅលោកអភិបាលខេត្ត - ក្រុង អោយចាត់វិធានការសមស្រប ដើម្បីការពារនូវផល ប្រយោជន៍ នៃរតនាគារ ។

**មាត្រា ៦** : លោកប្រធានមន្ទីរ ប្រធាននាយកដ្ឋាន បុគ្គលិក ប្រធានរតនាគារជាតិ ប្រធានរតនាគារខេត្ត - ក្រុង និង ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចទទួល បន្ទុកអនុវត្តតាមប្រកាសនេះ ចាប់តាំងពីថ្ងៃចុះ ហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**

* * *